# ជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

ខែតុលា ឆ្នាំ២០២០

## ឥន្ធនៈសម្រាប់ចម្អិន

គ្រួសារ ៦០,៩ ភាគរយ បានប្រើប្រាស់អុសជាប្រភពចម្បងសម្រាប់ចម្អិនម្ហូបអាហារ នៅតំបន់ទីប្រជុំជន ៣១,០ ភាគរយ និង ៧៨,៨ ភាគរយ នៅតំបន់ជនបទ ។

### ឥន្ធនៈសម្រាប់ចម្អិន ឆ្នាំ១៩៩៨-២០១៩




## មរណភាពទារក

អត្រាមរណភាពទារកមានចំនួន ១៨ នាក់ក្នុង ១.០០០ កំណើតរស់ នៅតំបន់ទីប្រជុំជន ១៦ នាក់ និង ១៩ នាក់ នៅតំបន់ជនបទ។

## មរណភាពមាតា

ផលធៀបនៃមរណភាពមាតាមានចំនួន ១៤១ នាក់ ក្នុង ១០០.០០០ កំណើតរស់។

## អាយុសង្ឃឹមរស់

អាយុសង្ឃឹមរស់គឺ ៧៦ ឆ្នាំ
សម្រាប់ប្រុសអាយុ ៧៤ ឆ្នាំ និង ស្រីអាយុ ៧៧ ឆ្នាំ។

## ពិការភាព

អត្រាប្រជាជនដែលមានពិការភាព (លំបាកខ្លះ) អាយុចាប់ពី ៥ឆ្នាំឡើង មានចំនួន ៤,៩ ភាគរយ នៅតំបន់ទីប្រជុំជន ៤,២ ភាគរយ និង ៥,៥ ភាគរយ នៅតំបន់ជនបទ។

### សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនក្នុងគ្រួសារ




## ភាពជាម្ចាស់កម្មសិទ្ធិលើលំនៅដ្ឋានផ្ទាល់ខ្លួន

គ្រួសារ ៩០,៧ ភាគរយ គឺជាម្ចាស់កម្មសិទ្ធិលើលំនៅដ្ឋានរបស់ពួកគេ នៅតំបន់ទីប្រជុំជន ៨១,៩ ភាគរយ និង ៩៦,០ ភាគរយ នៅតំបន់ជនបទ។

## ប្រភពបំភ្លឺសំខាន់ៗ

គ្រួសារ ៨៤,០ ភាគរយ កំពុងប្រើប្រាស់អគ្គិសនីជាប្រភពចម្បងសម្រាប់បំភ្លឺ នៅតំបន់ទីប្រជុំជន ៩៦,៩ ភាគរយ និង ៧៦.៤ ភាគរយ នៅតំបន់ជនបទ។

## ទឹកសម្រាប់ទទួលទាន

គ្រួសារ ៧៣,០ ភាគរយ មានប្រភពទឹកស្អាតសម្រាប់ទទួលទាន នៅតំបន់ទីប្រជុំជន ៨៣,៧ ភាគរយ និង ៦៦,០ ភាគរយ នៅតំបន់ជនបទ។

## បង្គន់អនាម័យ

គ្រួសារ ៨២,៨ ភាគរយ មានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ នៅតំបន់ទីប្រជុំជន ៩០,៤ ភាគរយ និង ៧៨,៣ ភាគរយ នៅតំបន់ជនបទ។

## ការប្រើប្រាស់អ៊ីនធឺណិត

គ្រួសារ ៤៥,៤ ភាគរយ កំពុងប្រើប្រាស់អ៊ីនធឺណិតនៅផ្ទះ នៅតំបន់ទីប្រជុំជន ៥៦,៤ ភាគរយ និង ៣៨,៨ ភាគរយ នៅតំបន់ជនបទ។

### ភាគរយប្រជាជនបែងចែក តាមរាជធានី ខេត្ត ឆ្នាំ២០១៩




**វិទ្យាស្ថានជាតិស្ថិតិ (វជស)**

លទ្ធផលជំរឿនចុងក្រោយអាចទាញយកតាមរយៈ QR code
ឬតាមរយៈវេបសាយ www.nis.gov.kh
ព័ត៌មានសម្រាប់ទំនាក់ទំនង មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ
លេខទូរសព្ទ៖ (៨៥៥) ១២ ៩៧៣ ៩៩៨ / (៨៥៥) ៩២ ៦៩២ ៥៤៧
National Institute of Statistics

របាយការណ៍ភាសាខ្មែរ

របាយការណ៍ភាសាអង់គ្លេស

## តួលេខសង្ខេប

| | |
|---|---|
| ចំនួនប្រជាជន (មិនា ឆ្នាំ២០១៩) | |
| ចំនួនសរុប | ១៥.៥៥២.២១១ នាក់ |
| ប្រុស | ៧.៥៧១.៨៣៧ នាក់ (៤៨,៧ ភាគរយ) |
| ស្រី | ៧.៩៨០.៣៧៤ នាក់ (៥១,៣ ភាគរយ) |
| ផលធៀបភេទ | ៩៥ នាក់ ប្រុស ក្នុងស្រី ១០០ នាក់ |
| ទីប្រជុំជន | ៦.១៣៥.១៩៤ នាក់ (៣៩,៤ ភាគរយ) |
| ជនបទ | ៩.៤១៧.០១៧ នាក់ (៦០,៦ ភាគរយ) |
| ដង់ស៊ីតេប្រជាជន | ៨៧ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ |


វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ

# ការប្រែប្រួលប្រជាជន

២០១៩ ១៥.៦ លាននាក់

២០០៨ ១៣.៤ លាននាក់

១៩៩៨ ១១.៤ លាននាក់



ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ (១៩៩៨-២០១៩)

## ចំនួនប្រជាជនសរុប តាមរាជធានី ខេត្ត ឆ្នាំ២០១៩




## សមាសភាពប្រជាជនបែងចែកតាមភេទ ឆ្នាំ២០១៩




## ពីរ៉ាមីតប្រជាជនកម្ពុជា ឆ្នាំ២០១៩




ពីរ៉ាមីតប្រជាជនបង្ហាញជាលក្ខណៈក្រាហ្វិចនូវអាយុ និងសមាសភាពភេទរបស់ប្រជាជន។ ជួរផ្ដេកបង្ហាញពីភាគរយប្រុស និងភាគរយស្រីក្នុងក្រុមអាយុនីមួយៗ ។

## ចំនួន និងភាគរយប្រជាជនបែងចែកតាមក្រុមអាយុ




0-១៤ ឆ្នាំ ៤.៥៧១.១៤0 នាក់

១៥-៥៩ ឆ្នាំ ៩.៦0២.៣៨៣ នាក់

៦0 ឆ្នាំឡើង ១.៣៧៨.៦៨៨ នាក់

**ផលធៀបអាយុក្នុងបន្ទុក**
ផលធៀបអាយុក្នុងបន្ទុកសរុបមាន ៦២,0 ភាគរយ នៅតំបន់ទីប្រជុំជន ៥១,២ ភាគរយ និង ៦៩,៩ ភាគរយ នៅតំបន់ជនបទ។

**សន្ទស្សន៍មនុស្សចាស់**
សន្ទស្សន៍មនុស្សចាស់មានចំនួន ៣0 នាក់ ដែលមានអាយុ ៦0 ឆ្នាំ ឡើង ក្នុងចំណោមមនុស្ស ១00 នាក់ដែលមានអាយុតិចជាង ១៤ ឆ្នាំ។




**អក្ខរភាព**
អត្រាអក្ខរភាពរបស់ប្រជាជនដែលមានអាយុចាប់ពី ៧ ឆ្នាំឡើង មានចំនួន ៨៨,៥ ភាគរយ ប្រុស ៩១,១ ភាគរយ និងស្រី ៨៦,២ ភាគរយ។

**ប្រជាជនបច្ចុប្បន្នកំពុងចូលរៀន ឆ្នាំ២០១៩**
ប្រមាណជាង ៩0 ភាគរយ នៃប្រជាជនដែលមានអាយុចាប់ពី ៦-១១ ឆ្នាំ និងអាយុ ១២-១៤ ឆ្នាំ បច្ចុប្បន្នកំពុងចូលរៀន។ ទោះជាយ៉ាងណា អត្រាបច្ចុប្បន្នកំពុងចូលរៀនមានកម្រិតទាបនៅក្នុងក្រុមអាយុដែលមានវ័យច្រើន។



| អាយុ ៦-១១ ឆ្នាំ | អាយុ ១២-១៤ ឆ្នាំ | អាយុ ១៥-១៧ ឆ្នាំ | អាយុ ១៨-២៤ ឆ្នាំ | អាយុ ២៥ ឆ្នាំឡើង |
|---|---|---|---|---|
| ៩0,៦ ភាគរយ | ៩១,៦ ភាគរយ | ៦៧,៦ ភាគរយ | ២0,៧ ភាគរយ | 0,៧ ភាគរយ |

**អត្រាចូលរួមកម្លាំងពលកម្ម**
៨១,៧ ភាគរយ នៃប្រជាជនទាំងអស់ដែលមានអាយុពី ១៥-៥៩ ឆ្នាំ ស្ថិតនៅក្នុងកម្លាំងពលកម្ម ប្រុស ៨៥,៨ ភាគរយ និងស្រី ៧៧,៩ ភាគរយ។

**អត្រាគ្មានការងារធ្វើ**
១,២ ភាគរយ នៃប្រជាជនដែលមានអាយុពី ១៥-៥៩ ឆ្នាំ គ្មានការងារធ្វើ ប្រុស ១,១ ភាគរយ និងស្រី ១,៣ ភាគរយ។